# កម្ពុជា៖ ល្បែងស៊ីសងចាប់ផ្តើមទៀតហើយ ប៉ុន្តែអ្នកក្រនៅតែក្រ

ដោយ ខាន់ សុភីរម្យ

ប៉ោយប៉ែត, ប្រទេសកម្ពុជា (អាយភីអេស) - ថៅកែល្បែងនៅទីប្រជុំជនជាប់ព្រំដែននេះ អាចមើលឃើញឱកាសដើម្បីស្តារមុខជំនួញរបស់គេឡើងវិញហើយ អាស្រ័យដោយព្រំដែនកម្ពុជា-ថៃត្រូវគេបើកឡើងវិញ ហើយប្រទេសទាំងពីរកំពុងតែផ្សារភ្ជាប់នូវទំនាក់ទំនងរវាងគ្នាឡើងវិញនោះ។ ប៉ុន្តែ សម្រាប់កម្មករជនជាតិថៃ និងខ្មែរនៅទីនេះ ជីវិតរបស់គេនៅតែរួមរឹតដោយភាពក្រីក្រដដែល។

រដ្ឋមន្ត្រីការបរទេសថៃ លោក ស៊ុរ៉ាកៀត សាធីរ៉ាថៃ បាននិយាយថាប្រទេសថៃ និងកម្ពុជាបានព្រមព្រៀងគ្នាកាលពីថ្ងៃទី១១ខែមេសានេះ ដើម្បីស្តារឡើងវិញនូវទំនាក់ទំនងការទូតពេញលេញ បន្ទាប់ពីទំនាក់ទំនងនេះត្រូវធ្លាក់ចុះក្រោយពីមានកុបកម្មប្រឆាំងនឹងថៃកាលពីខែមករាមក។ តាមពិត កិច្ចប្រព្រៀងធ្វើបានធ្វើឡើង បន្ទាប់ពីព្រំដែននៃប្រទេសទាំងពីរបានបើកឡើងវិញអស់ជាច្រើនសប្តាហ៍មកហើយនោះ។

លោកបានប្រាប់អ្នកយកពត៌មានថា៖ "(យើង)នឹងស្តារទំនាក់ទំនងធម្មតាឡើងវិញ ដើម្បីជាកាដូ 'ស៊ុងក្រាន' (ឆ្នាំថ្មី)សម្រាប់ជនជាតិថៃ និងកម្ពុជា អាស្រ័យដោយប្រទេសកម្ពុជាបានបង្ហាញនូវភាពស្មោះត្រង់ដោយបានសងការខូចខាតចំនួន២៥០លានបាត (ស្មើនឹង៥,៩៥លានដុល្លាអាមេរិក) ចំពោះការបំផ្លាញស្ថានទូតថៃក្នុងអំឡុងពេលនៃកុបកម្ម។"

ស៊ុងក្រាន (ភាសាខ្មែរ៖ មហាសង្ក្រាន) គឺជាថ្ងៃចូលឆ្នាំរបស់ថៃ ដែលប្រារព្ធធ្វើឡើងនៅថ្ងៃទី១៣មេសា។ ដោយឡែក នៅឆ្នាំនេះមហាសង្ក្រាននៅប្រទេសកម្ពុជា ធ្វើឡើងនៅថ្ងៃទី១៤មេសា។

អាស្រ័យដោយកាស៊ីណូត្រូវគេហាមឃាត់នៅក្នុងប្រទេសថៃ ហើយអ្នកញៀនល្បែងថៃមិនអាចលេងនៅស្រុករបស់ខ្លួន ជនជាតិថៃជាច្រើននាក់នាំគ្នាចេញទៅក្រៅប្រទេស ដើម្បីបង្ហិនលុយនៅសល់របស់គេ ឬប្រាក់សន្សំដែលបានមកដោយលំបាក នៅក្នុងវង់បៀរ ទូរហ្គេម ឬល្បែងស៊ីសងដទៃទៀត។

ពួកភ្ញៀវ ត្រូវបានទទួលដោយក្មេងសុំទានរាងកាយស្គមស្គាំងជាច្រើននាក់នៅប៉ោយប៉ែត ក្នុងស្រុកអូរជ្រៅនៃប្រទេសកម្ពុជា មុននឹងពួកគេចូលទៅប៉ុស្តិ៍ត្រួតពិនិត្យនៅព្រំដែនកម្ពុជា។ ជំនួសពាក្យដាក់ថា "ស្វាគមន៍ " មានផ្លាកសញ្ញាចម្លែកមួយសរសេរជាភាសាថៃថា៖"ការឆ្លងព្រំដែនដើម្បីទៅលេងល្បែងមិនមានសុវត្ថិភាពសម្រាប់ជីវិតរបស់អ្នកឡើយ។"

នេះគឺជាវិធីមួយរបស់រដ្ឋាភិបាលថៃ ដើម្បីរារាំងប្រជាជនរបស់ខ្លួនកុំឱ្យមកលេងល្បែងនៅទីនេះ និងដើម្បីទប់ស្កាត់ការបង្ហិនបង្ហោចប្រាក់រហូតដល់ទៅជិត២០០០លានដុល្លា នៅកាស៊ីណូឆើតតែមិនសូវថ្លៃថ្នូរនៅតាមព្រំដែននោះ។

"មានជនជាតិថៃជាង១០០០នាក់ ឆ្លងព្រំដែនជារៀងរាល់ថ្ងៃ," លោក វ៉ាន់ឆៃ តូផន ដែលជាមេប៉ូលីសនៅស្រុកអារញ្ញប្រទេសក្នុងខេត្តស្រះកែវជាប់ប៉ោយប៉ែត បាននិយាយ។

បរិវេណល្បែងដែលមានប្រវែងមួយគីឡូម៉ែត្រនេះ មានកាស៊ីណូចំនួនប្រាំពីរ និងមួយទៀតកំពុងសាងសង់ ដោយមានសួនស្មៅរលោងស្រិល សណ្ឋាគារទំនើបៗ ហាងលក់ទំនិញមានម៉ាស៊ីនត្រជាក់ កន្លែងម៉ាស្សា និងបនពេស្យាចារ្យជាច្រើន ។

ប៉ុន្តែ នៅខាងក្រៅរបងកាស៊ីណូ មានទិដ្ឋភាពផ្ទុយស្រឡះ ។ តាមផ្លូវដីក្រខ្វក់ គំនរសម្រាមត្រូវគេទុកចោលពាសវាល ដោយគ្មានអ្នកមកប្រមូល ព្រមជាមួយនឹងលំនៅដ្ឋានរយីករយាកយ៉ាងច្រើនដេរដាស ។

ប៉ុន្តែ រដ្ឋាភិបាលថៃកាន់តែព្រួយបារម្ភខ្លាំងឡើងចំពោះប្រាក់ដ៏ច្រើនសន្ធឹកសន្ធាប់ដែលប្រជាពលរដ្ឋរបស់ខ្លួនចំណាយនៅកាស៊ីណូប្រទេសជិតខាង ។ មានកាស៊ីណូនៅតំបន់ព្រំដែនយ៉ាងហោចណាស់បីកន្លែងទៀតនៅប្រទេសកម្ពុជា និងកាស៊ីណូជាច្រើនទៀតនៅប្រទេសភូមា និងឡាវ ។

ការសិក្សាមួយដោយសកលវិទ្យាល័យជូឡាឡុងកនកាលពីឆ្នាំមុនបានឱ្យដឹងថា ប្រាក់ដែលជនជាតិថៃចំណាយនៅកាស៊ីណូទាំងនោះ មានចំនួនពី ៧១ ០០០ ទៅ ៨៤ ០០០លានបាត ( ស្មើនឹង ១៦៩០ ទៅ ២០០០ លានដុល្លាអាមេរិក) ក្នុងមួយឆ្នាំ ។

ប្រការនេះ ព្រមជាមួយប្រការដទៃទៀត បានបំផុសឱ្យមានការពិភាក្សាដេញដោលមួយនៅប្រទេសថៃ អំពីថាតើប្រទេសនេះគួរតែបើកឱ្យមានកាស៊ីណូនៅក្នុងប្រទេសឬយ៉ាងណា ។ កន្លែងមួយ ដែលគេលើកឡើងជាទូទៅនោះ គឺលទ្ធភាពនៃការបង្កើតកាស៊ីណូនៅតំបន់ទេសចរបាតតាយ៉ាភាគខាងត្បូងប្រទេស ។

អ្វីដែលគួរឱ្យភ្ញាក់ផ្អើលនៅពេលនេះ គឺភាពទាក់ទាញនៃកាស៊ីណូប៉ោយប៉ែត ហាក់ដូចជាធ្វើឱ្យកម្មករថៃដែលមានចំណូលទាបនៅស្រុកអារញ្ញប្រទេស ធ្លាក់ខ្លួនជាប់បំណុលគេដោះមិនរួច ។

អ្នកភូមិម្នាក់នៅអារញ្ញប្រទេសឈ្មោះសាម៉ៃ គង់ចាម៉ន បាននិយាយថាវាមិនមែនជាការងាយស្រួលទេ ដើម្បីឱ្យដឹងថាតើមានជនជាតិថៃនៅស្រុកនេះប៉ុន្មាននាក់ដែលមកលេងល្បែងនៅប៉ោយប៉ែតនោះ ។ គាត់និយាយថា: "វាជារឿងកិត្តិយស ហើយគេមិនដែលប្រាប់យើងថាតើគេចាញ់ល្បែងអស់លុយ ឬទ្រព្យប៉ុន្មាននោះឡើយ ។ ប៉ុន្តែ ពួកគេនៅតែបន្តបំផ្លាញជីវិតរបស់គេតទៅទៀត ។"

កម្មករថៃម្នាក់នៅផ្សាររុងគ្បឿក្នុងដីថៃជាប់ប៉ោយប៉ែត បាននិយាយថាគាត់តែងតែមកលេងល្បែងនៅកាស៊ីណូជាញឹកញាប់ ។ "ខ្ញុំនឹងទៅទីនោះ នៅពេលដែលខ្ញុំមានលុយយ៉ាងតិច៥០០បាត ( ប្រមាណ១២ ដុល្លាអាមេរិក) នៅក្នុងហោប៉ៅរបស់ខ្ញុំ," កម្មកររូបនោះបាននិយាយ ដោយសុំមិនបញ្ចេញឈ្មោះ ។

គាត់បានបន្តទៀតថា:"ខ្ញុំកម្រឈ្នះណាស់ ប៉ុន្តែខ្ញុំតែងតែបានលុយធីប( លុយទឹកតែ)ពីអ្នកលេងជាអ្នកមាន ។ ពួកគេតែងតែឱ្យលុយខ្ញុំ ព្រោះគេនិយាយថាមុខខ្ញុំមានសំណាង ។ ប៉ុន្តែ នៅទីបញ្ចប់ពួកគេក៏ទទួលវាសនាដូចខ្ញុំដែរ គឺចាញ់អស់រលីងមួយថ្ងៃហ្នឹង ។"

កាលពីក្នុងអំឡុងសម័យសង្គ្រាម ប៉ោយប៉ែតគឺជាច្រកឆ្លងកាត់នៃជនភាសខ្លួន និងជាផ្លូវរត់ពន្ធរបស់ជនជាតិថៃដែលរកស៊ីនៅផ្សាររង់ក្លឿជាប់នោះ។ នៅចុងឆ្នាំ១៩៩៨ ប៉ោយប៉ែតត្រូវបានកំណត់ជាច្រកទ្វារព្រំដែនអន្តរជាតិរវាងកម្ពុជា និងថៃ។

នៅឆ្នាំនោះដែរ នាយករដ្ឋមន្ត្រីកម្ពុជា លោក ហ៊ុន សែន បានចាប់ផ្តើមគម្រោងមួយ ដើម្បីជម្រុញនូវការវិនិយោគទុនបរទេសនៅក្នុងប្រទេស ដោយស្វែងរកប្រាក់ក្រៅប្រទេសតាមរយៈការចំណាយនៅក្នុងកាស៊ីណូតាមព្រំដែនកម្ពុជា-ថៃ។ កាស៊ីណូទីមួយនៅប៉ោយប៉ែត បានបើកទ្វារនៅឆ្នាំ១៩៩៩ ហើយកាស៊ីណូទីប្រាំពីរបានចាប់ផ្តើមដំណើរការនៅចុងឆ្នាំ២០០១។

ការកសាងកាស៊ីណូ ក៏បានបង្កនូវការកើនឡើងនៃចំនួនប្រជាជននៅទីប្រជុំជនប៉ោយប៉ែតដែរ។ តាមសម្តីស្មៀនឃុំថ្មីរបស់ប៉ោយប៉ែតឈ្មោះ សាន សៀនហ៊ួ ដែលត្រូវបានតែងតាំងដោយក្រសួងមហាផ្ទៃ ចំនួនប្រជាជននៅទីនេះ បានកើនឡើងពី៩២៨៤គ្រួសារនៅក្នុងជម្រើនឆ្នាំ១៩៩៨ រហូតដល់ទៅជាង ១០០ ០០០ គ្រួសារ។

ប៉ុន្តែ គ្រូពេទ្យម្នាក់នៅមន្ទីរពេទ្យស្រុកអូរជ្រៅបាននិយាយថា ប្រជាជនជាច្រើននាក់បានមក ប៉ោយប៉ែតដោយខកបំណង។

"មនុស្សជាច្រើននាក់សង្ឃឹមថាមករកការងារធ្វើនៅកាស៊ីណូ ប៉ុន្តែធ្លាក់ខ្លួនត្រូវគេរត់ពន្ធទៅប្រទេសថៃធ្វើជាកម្មករសំណង់ខុសច្បាប់ ឬធ្វើជាអ្នករកស៊ីផ្លូវភេទនៅក្នុងបនពេស្យាចារ្យ," គ្រូពេទ្យរូបនោះបាននិយាយ ដោយសុំមិនបញ្ចេញឈ្មោះ។

"អ្នកមករស់នៅប៉ោយប៉ែតមួយចំនួនធំនៅពេលបច្ចុប្បន្ននេះ គឺជាកសិករដែលគ្មានដីធ្លីមកពីខេត្តផ្សេងៗ ដើម្បីរត់ពីភាពអត់ការងារធ្វើ និងទុក្ខវេទនា," គាត់បាននិយាយ។

លោកគ្រូពេទ្យបានបន្ថែមទៀតថាៈ"មានក្មេងជាច្រើននាក់ក៏បានមកដល់ទីនេះដែរ ហើយពួកគេធ្វើជាអ្នកសុំទានជនបរទេសដ៏ច្រើននាក់ដែលមកលេងល្បែងនៅកាស៊ីណូ ឬធ្វើជាអ្នកយាមឡាន រួចសុំលុយពួកអ្នកលេងល្បែង ដើម្បីកុំឱ្យគេលួចឡានរបស់គេ។"

"ភាគច្រើនក្មេងទាំងនេះរៀនបានតិចណាស់ ហើយគ្មានការគាំទ្រពីគ្រួសារទេ។ (ពួគេនាំគ្នា) ហិតកាវ ឬប្រើ(ថ្នាំញៀន)អាំហ្វេតាមីនយ៉ាងគគ្រឹកគគ្រេង ដើម្បីបំបាត់នូវការស្រេកឃ្លាន ភាពឯកោ និងការដែលបាត់បង់ការស្រឡាញ់ពីគ្រួសារ," លោកគ្រូពេទ្យបាននិយាយ។

លោក សម រង្ស៊ី ដែលជាអតិតរដ្ឋមន្ត្រីហិរញ្ញវត្ថុ និងប្រធានគណបក្សសម រង្ស៊ី បានស្នើឱ្យរដ្ឋាភិបាលលោក ហ៊ុន សែន ធ្វើការពន្យល់ហេតុផលផ្នែកសេដ្ឋកិច្ចចំពោះការជ្រើសរើសការវិនិយោគទុនទៅលើល្បែងស៊ីសងឆ្លងដែន ដើម្បីជម្រុញនូវការរីកចម្រើនផ្នែកសេដ្ឋកិច្ចនោះ។

"(មធ្យោបាយមួយនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់រដ្ឋាភិបាល) នាពេលបច្ចុប្បន្ននេះ គឺល្បែងស៊ីសង ក្រៅអំពីការកាប់ព្រៃឈើ, ការជួញដូរគ្រឿងញៀន, ពេស្យាចារ្យ និងឧស្សាហកម្មដោយប្រើកម្លាំងពលកម្មថោក។ ការរីកចម្រើនបែនេះ វាមិនរឹងមាំទេ," លោក សម រង្ស៊ី បាននិយាយ។

"(ការខាតបង់) ផ្នែកសង្គមដែលទាក់ទិននឹងការរីកចម្រើនបែបនេះ នឹងប្រែក្លាយទៅជា (ការខាត-បង់) ផ្នែកសេដ្ឋកិច្ចដ៏ធ្ងន់ធ្ងរក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ ដែលបណ្តាលឱ្យសណ្តាប់ធ្នាប់សង្គមត្រូវបំផ្លិច-បំផ្លាញ," លោក បានបន្ថែម។

(បញ្ជាក់ : លោក ខាន់ សុភិរម្យ បានសរសេរអត្ថបទនេះ ក្រោមការឧបត្ថម្ភរបស់កម្មវិធីអាហា-រូបករណ៍សារពត៌មាន អាយភីអេស-រ៉កខេហ្វិលឡឺ ហ្វោនដេស្ហិន ក្រោមប្រធានបទៈ "ទន្លេមេគង្គរបស់យើងៈ ទស្សនៈវិស័យមួយ ក្នុងដំណាក់កាលនៃពិភពលោកភាវូបនីយកម្ម"។)